## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តស្វាយរៀង
ស្រុករំដួល
ឃុំកំពង់ចក
លេខ:០០១/១៥.ឃ.ក.

# ដីកា

## ស្តីពី

## ការបង្ការ និងទប់ស្កាត់អំពើហិង្សារួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំកំពង់ចកស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០១៥។
- យោងលទ្ធផលសិក្ខាសាលាស្តីពី"វិធានការរួមស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី០៦ខែកក្កដា ឆ្នាំ២០១៥ ។

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និង ប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋជារួមក្នុងឃុំកំពង់ចក ដូច្នេះ ក្រុមប្រឹក្សាឃុំកំពង់ចក

### សម្រេច

**ប្រការ១៖** ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រីសិទ្ធិកុមារនិងបង្ការអំពើហិង្សាលើដៃគូស្និទ្ធស្នាល ព្រមទាំងលើកកម្ពស់សុខុមាលភាពនិងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់ និង សុវត្ថិភាពក្នុងឃុំកំពង់ចកទាំងមូល ។

**ប្រការ២៖** ដីកានេះមានវិសាលភាពអនុវត្តទៅលើ អ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬបង្កការរំខាន ឬបង្កហិង្សានានារួមទាំងទៅលើដៃគូស្និទ្ធស្នាលដូចជាប្តីប្រពន្ធ សង្សា ព្រមទាំងអ្នកផលិត អ្នកលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យជនឬនៅទីកន្លែងមួយចំនួនក្នុងឃុំកំពង់ចកដែលបានកំណត់ក្នុងដីកានេះ។

**ប្រការ៣៖**ហាមប្រើឲ្យទិញ ឬលក់គ្រឿងស្រវឹងឲ្យក្មេងចាប់ពីអាយុ១៥ឆ្នាំចុះក្រោម។
បើជនណាប្រព្រឹត្តផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ (មួយម៉ឺនរៀល) ទៅ៥០០០០៛ (ប្រាំម៉ឺនរៀល) ។

**ប្រការ៤៖**អ្នកពិសារគ្រឿងស្រវឹងបង្កហិង្សាត្រូវផាកពិន័យជាទឹកប្រាក់ពី៥០០០០៛(ប្រាំម៉ឺនរៀល) ទៅ ១០០០០០៛ (មួយសែនរៀល) ។ ចំពោះបទឧក្រិដ្ឋត្រូវចាត់វិធានការទៅតាមច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ។

**ប្រការ៥៖**អ្នកដែលប្រើប្រាស់គ្រឿងស្រវឹងហើយបើកបរដើរស្រែកឡូឡា ឬ ដេរប្រមាថអ្នកដទៃ ឬ ប្រើឧបករណ៍បំពងសំឡេងចាប់ពីម៉ោង១១: ៣០ នាទី យប់តទៅ ត្រូវផាកពិន័យពី២០០០០៛ (ពីរម៉ឺនរៀល ) ទៅ ៥០០០០៛ (ប្រាំម៉ឺនរៀល) ។

**ប្រការ៦៖**មិនអនុញ្ញាតអោយមានការលក់ផលិតផលគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹងគ្រប់ប្រភេទនៅ តាមបរិវេណវត្តអារាម សាលារៀន មណ្ឌលសុខភាព។
បើជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ ទៅ (មួយម៉ឺនរៀល) ៥០០០០៛ (ប្រាំម៉ឺនរៀល) ។

**ប្រការ៥៖** រាល់ការផលិតគ្រឿងស្រវឹងត្រូវមានការត្រួតពិនិត្យ និង អនុញ្ញាតដោយប្រធានក្រុមប្រឹក្សាឃុំ ។

បើជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ ទៅ (មួយម៉ឺនរៀល) ៥០០០០៛ (ប្រាំម៉ឺនរៀល) ។

**ប្រការ៧៖**ត្រូវកោះហៅអ្នកពិសារគ្រឿងស្រវឹងនិង ប្រព្រឹត្ត អំពើ ហិង្សា ដែលផ្ទុយ នឹង ប្រការ ខាងលើ មកអប់រំ លើកទី១ លើកទី២ហើយលើកទី៣នៅមិនរាងចាល លើក ទី ៤ នឹង ត្រូវ ផាកពិន័យតាមប្រការខាងលើ ។

**ប្រការ៨៖**ការផាកពិន័យ និង ការចុះត្រួតពិនិត្យជាតួនាទីរបស់ក្រុមប្រឹក្សាឃុំ និង ប៉ុស្តិ៍រដ្ឋបាលហើយការអប់រំណែនាំត្រូវធ្វើឡើងនៅសាលាឃុំ ឬ ប៉ុស្តិ៍រដ្ឋបាល ។

**ប្រការ៩៖**អជ្ញាធរមូលដ្ឋានមេភូមិ សមាជិកក្រុមប្រឹក្សាឃុំ ប៉ូលីសប៉ុស្តិ៍រដ្ឋបាល គ្រូបង្រៀន បុគ្គលិកសុខាភិបាល យុវជន និង ព្រះសង្ឃត្រូវចូលរួមផ្សព្វផ្សាយដល់ប្រជាជនក្នុងសហគមន៍ឲ្យបានជ្រួតជ្រាប ។

**ប្រការ១០៖** ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅឃុំកំពង់ចក ថ្ងៃទី ០៥ ខែ ០៧ ឆ្នាំ២០១៥

ឃុំ កំពង់ចក

**សន_សារិន**